ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ថ្ងៃព្រហស្បតិ៍ ១០កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៨

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## ការប្រារព្ធទិវាកុមារអន្តរជាតិ ១មិថុនា ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០១៨

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក) មានកិត្តិយសសូមជម្រាបជូនសាធារណជនទូទៅជ្រាបថា នាថ្ងៃព្រហស្បតិ៍ ២រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ នៅសាលមហោស្រពនៃមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ នឹងមានរៀបចំពិធីមីទ្ទិញអបអរសាទរ *ខួបលើកទី៦៩ ទិវាកុមារអន្តរជាតិ ១មិថុនា* ក្រោមប្រធានបទ *"រួមគ្នាការពារកុមារដើម្បីអភិវឌ្ឍគ្រួសារ និងសង្គមជាតិ" ខួបលើកទី១៧ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា* ក្រោមប្រធានបទ *"ទប់ស្កាត់គ្រោះថ្នាក់ការងារ និងភាពងាយរងគ្រោះផ្នែកសុខភាពសម្រាប់កម្មករនិយោជិតវ័យក្មេង ដើម្បីលុបបំបាត់ពលកម្មកុមារ"* និង*ទិវាកុមារកម្ពុជា ឆ្នាំ២០១៨* ដើម្បីរំលឹកដល់សិទ្ធិជាមូលដ្ឋានរបស់កុមារ និងបង្ហាញពីការប្តេជ្ញាចិត្ត យ៉ាងមោះមុត ក្នុងការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ដើម្បីបន្តជំរុញលើកកម្ពស់ការអនុវត្តសិទ្ធិកុមារ និងការអបអរសាទរលទ្ធផលការងារលើវិស័យកុមារ ដែលរាជរដ្ឋាភិបាលកម្ពុជាសម្រេចបានក្នុងនាមជាប្រទេសហត្ថលេខី នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ។

ពិធីមិទ្ទិញដ៏អធិកអធមនេះនឹងប្រព្រឹត្តិទៅក្រោមអធិបតីភាព លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច តំណាងដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានកិត្តិយសក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។ ក្នុងនោះដែរក៏មានការអញ្ជើញជាកិត្តិយសពីភ្ញៀវជាតិ អន្តរជាតិ អង្គទូត លោកគ្រូ អ្នកគ្រូ កុមារា កុមារី សិស្សានុសិស្សមកពីសាលារដ្ឋ សាលាឯកជន មណ្ឌលថែទាំកុមាររបស់រដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងកុមារតាមសហគមន៍ សរុបចំនួន ៣៤០០នាក់។

ដើម្បីញ៉ាំងឱ្យទិវាដ៏មានសារៈសំខាន់នេះ កាន់តែមានខ្លឹមសារ និងមានការយកចិត្តទុកដាក់ខ្ពស់ពីថ្នាក់ដឹកនាំរាជរដ្ឋាភិបាល អ្នករៀបចំគោលនយោបាយ និងអ្នកពាក់ព័ន្ធជាមួយកុមារ អគ្គលេខាធិការដ្ឋាន ក.ជ.ក បានសហការរៀបចំឱ្យមានសកម្មភាពមួយចំនួនរបស់កុមាររួមមានៈ មតិចំណាប់អារម្មណ៍របស់តំណាងកុមារក្នុងការបញ្ចេញនូវទស្សនៈ និងលើកឡើងនូវសំណូមពរនានាដែលពួកគេបានរកឃើញ។ លើសពីនេះនឹងមានសកម្មភាពកំសាន្តផ្សេងៗដែលសម្តែងដោយក្រុមកុមារដូចជា របាំជូនពរ ចាប៉ីដងវែង ការប្រគុំតន្ត្រី និងសិល្បៈសៀកជាដើម។ល។ ស្របពេលនោះដែរក៏មានការរៀបចំប្រឡងគូរគំនូរ ដើម្បីឲ្យកុមារបានបង្ហាញសមត្ថភាព និងទេពកោសល្យរបស់ខ្លួន។

ជាមួយនឹងការរៀបចំមីទ្ទិញនេះ រាជរដ្ឋាភិបាលកម្ពុជាក៏បានជំរុញឱ្យមានការរៀបចំការសម្សាន្តសប្បាយសម្រាប់កុមារនៅតាមក្រសួង ស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាលទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងគ្រប់មជ្ឈដ្ឋានដើម្បីឱ្យកុមារនៅទូទាំងប្រទេសកម្ពុជាទទួលបាននូវភាពសប្បាយរីករាយក្នុងថ្ងៃទិវារបស់ពួកគេ។

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ អាគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារៈ ០២៣ ២១៨ ០១៨